# កំណាព្យអប់រំ

# អារ្យធម៌ខ្មែរ



ដោយ បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ឆ្នាំ ២០២៥

# អារម្ភកថា

## (បទកាកគតិ)

១) សុភមស្តុ សួស្តីសព្វមុ- ង្គលដ៏ថ្លៃថ្លា
មានព្រះជយា សទ្ធាតិរា សូមលើកហត្ថា
គោរពញាតិមិត្ត។

២) អរិយធម៌ខ្មែរ ជាតិយើងពូកែ វប្បធម៌ពិតៗ
ព្រហ្មញ្ញសាសនា ភាសាគំនិត ឈាមជ័រពិពិធ
អ្នកសាងអង្គរ។

៣) ខ្ញុំនឹងរាយរាប់ ទុកជាសន្ទាប់ ខ្មែរពេញនគរ
ឱ្យបានយល់ដឹង ខំប្រឹងពូនគរ មរតកបវរ
ខ្មែរត្រូវការពារ។

៤) ប្រាសាទបុរាណ ខ្មែរធ្លាប់ថ្កើងថ្កាន គ្រប់ពេលវេលា
សិល្បៈតន្ត្រី ប្រពៃណីជា របាំទ្រព្យ
កូនខ្មែរត្រូវដឹង។

ភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៥

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# អារម្ភកថា

## (បទកាកគតិ)

១) សូមលើកហត្ថា  រំឭកឧបការ  លោកអ្នកមានគុណ
បិតាមាតា  ប្រសើរលើសលន់  មហាសែនធ្ងន់
លើទ្វីបលោកា។

២) ព្រះនាមហង់ជួន  ប្រាជ្ញាមាំមួន  ទឹកចិត្តស្នេហា
ក្រោយថ្ងៃរំដោះ  ប្រាំពីរមករា  ស្តារខឿនសិក្សា
អប់រំឡើងវិញ។

៣) ពេលនេះបន្ត  តំណែងតំណ  បិតាបំពេញ
ជារដ្ឋមន្ត្រី  អប់រំពេញលេញ  ប្រៀបចិត្តពោរពេញ
ដោយក្តីមោទនៈ។

៤) ប្រាំឆ្នាំកន្លង  កិច្ចការប្រឡង  បានជោគជ័យជាក់
កំណែទម្រង់  បន្ថយឧបសគ្គ  មិននៅស្ទើរស្ទាក់
លាន់ឮដូចផ្គរ។

៥) ដំណើរទៅមុខ  ធនធានឈានមុខ  មូលដ្ឋានគាំទ្រ
សាងជំនាន់ថ្មី  ពូជពង្សអង្គរ  ទូទាំងនគរ
ធានាស្តុកស្តម្ភ។

៦) ធ្វើច្រើនឈប់តិច  បំពេញភារកិច្ច  រិះគិតរៀបចំ
ស៊ូទ្រាំនឿយហត់  អំណត់លត់ដំ  ជ្រោងសសរស្តម្ភ
អប់រំប្រសើរ។

៧) សតវត្សរ៍២១ ត្រូវពូនជ្រំជ្រួយ សមត្ថភាពប្រើ
បច្ចេកវិទ្យា ជំនាញបម្រើ សព្វការសារពើ
ជាឌីជីថល។

៨) វិនិយោគអប់រំ ជាធនធានធំ ជូនជាតិសកល
ជំរុញបង្កើន សមិទ្ធផល មិនអាចស្កប់ស្កល់
នាយុគសម័យ។

៩) សូមកោតសរសើរ ចំពោះដំណើរ ប្រឡងថ្មីៗ
លោកគ្រូអ្នកគ្រូ គរុសិស្សក្តី រួមមានស្នាដៃ
ទុកជាសាវតារ។

១០) អប្បមាទជំនួយ អនុរក្សប្រឹងជួយ ទាន់សភាពការណ៍
គ្មានលួចចម្លង គ្មានយកឯកសារ សុវត្ថិវិញ្ញាសា
គ្មានការបែកធ្លាយ។

១១) អរគុណ អរគុណ ភារកិច្ចធ្ងន់ យើងបានរែកស្ពាយ
លទ្ធផលប្រឡង ឆ្នាំនេះពណ្ណរាយ ប្រជារីករាយ
ទទួលសាទរ។

១២) កុសលខ្ញុំសាង សូមជូនសំណាង សួស្តីបវរ
គ្រប់ផ្នែកពាក់ព័ន្ធ និង អ ប ព គោរពជូនពរ
ជោគជ័យគ្រប់គ្រា។

ទីស្តីការក្រសួងអប់រំ យុវជន និងកីឡា ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៥

លោកជំទាវ **ទន់ សាអ៊ឹម**

អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា

# វប្បធម៌ អារ្យធម៌ខ្មែរ

១) ជនជាតិខ្មែរ ល្បីពូកែ ខាងវប្បធម៌
មានឈាមជ័រ អារ្យធម៌ ពីបុរាណ
ត្រូវខិតខំ អភិរក្ស ឱ្យថ្កើងថ្កាន
ខ្មែរគ្រប់ប្រាណ ត្រូវព្យាយាម ចងសច្ចៈ។

២) ប្រវត្តិសាស្ត្រ ពង្សាវតារ ចារទុកមក
ត្រូវរិះរក សិក្សារៀន ធបុរៈ
**ពីហ្វូណន** មក**ចេនឡា** **លិទ្ធបុរៈ**
រួមឆន្ទៈ វប្បធម៌ ពីទេពី។

៣) អក្សរខ្មែរ យើងត្រូវតែ ថែរក្សា
ជាភាសា ចាស់វស្សា នៅអាស៊ី
មានសិលា ចារឹកទុក ដែលគ្មានពីរ
ពេញប្រឹថពី ទុកជាទី ពីព្រេងព្រឹទ្ធ។

៤) **អង្គរបុរី** និវាសដ្ឋាន ដ៏ចំណាស់
កើតខ្មែរចាស់ ដែលកែផ្លាស់ ពីសំស្រ្កឹត
ជូនតាខ្មែរ យកទៅកែ ជាខ្មែរពិត
ឯសំស្រ្កឹត ជាពិសិដ្ឋ និងទេវា។

៥) ខាងសាសនា ព្រះព្រហ្មញ្ញ និងព្រះពុទ្ធ
មាំមោះមុត ជាជំនឿ ពីឥណ្ឌា
វត្តគំនូរ សិលាចា រឹកពុះពារ
ខ្មែរគ្រប់គ្នា ចេះទំពា ដោយមេត្រី។

៦) ប្រាសាទខ្មែរ ព្រះវិស្ណុ នៅ**ភ្នំដា**
ក្បាច់រចនា បថសិក្សា អង្គរបុរី
មានអូរកែវ កំពង់ផែ ដ៏ល្បាញល្បី
ដែលគប្បី អភិរក្ស អារ្យធម៌។

៧) ទឹកមេគង្គ ពីស្ទឹងត្រែង វិត្ថារ
**សម្ភុបុរៈ** **លិង្គបុរី** ដែនវប្បធម៌
ស្តេចនគរ **ភវវម៌្ម** ផ្សព្វផ្សាយធម៌
បញ្ចពណ៌ ស្រស់បវរ ដែនវម៌្ម។

៨) **ចិត្រាសេន** វីរក្សត្រ **មហេន្ទ្រ**
ដូចឥន្ទ្រ បុត្រព្រះបាទ **វីរវម៌្ម**
មានសិលា ចារឹកអម ដោយអាត្ម័ន
សម្គាល់យ័ន្ត ជាសីមា ដែនបុរៈ។

៩) សតវត្ស ទីប្រាំពីរ ធានីថ្មី
សំបូរី ព្រៃគុកឮ សានបុរៈ
**ឦសានវម៌្ម** ព្រះរាជា ដូចសិវៈ
មានតេជៈ អាណាចក្រ ដែនទាំងអស់។

១០) រូបសម្ផស្ស ស្រស់ត្រកាល និងស្មោះស្ម័គ្រ
កតញ្ញុត ធម៌ប្រត្យក្ស រដ្ឋបុរស
មានគុណធម៌ អក្សរសាស្ត្រ ចេះឥតខ្ចោះ
ព្រះទ័យស្មោះ គ្មានឱរស ណាអាចធៀប។

១១) សិល្បៈប្រា សាទព្រៃក្មេង បយ័ង្គោ
ហាន់ជយោ មានទំនោរ សុក្រឹតភាព
មហាក្សត្រ ភវវម៌្ម ២គ្មានប្រៀប
ពលានុភាព បីដូចភ្នំ ព្រះសុមេរុ។


youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

១២) **ជ័យវម៌្ម** **ទី១**បាន ឡើងសោយរាជ្យ
ជានីរាជ នៅអម ឥន្ទ្របុរ
ជឿសាសនា លិង្គឥស្សូរ គ្មានងាករេ
ព្រះបុព្វ កម្រតាង អញស្វយម្ភូ។

១៣) រចនា បថ**អណ្ដែត** លើប្រាសាទ
សមមាត្រ សមតា បានគិតគូរ
ទេវស្ថាន សក្ការៈ ពីវត្តភូ
ព្រះសម្ភុ ក្រុងបុរាណ នៅក្រចេះ។

១៤) ខ្មែរបង្កើត បានលេខសូន្យ ចាស់ជាងគេ
ឥតរៀចវេរ ដើម្បីផ្សំ ជាចំណេះ
ទួលកំណប់ ត្រពាំងព្រៃ ខេត្តក្រចេះ
សព្វថ្ងៃនេះ តម្កល់ទុក រៀនបន្ត។

១៥) សតវត្ស ទីប្រាំបី មានបញ្ហា
ដោយសារចា រឹកមានពីរ តែអក្សរ
ខុសគ្នាខ្លាំង ពីខ្មែរចាស់ មុនអង្គរ
ជាអក្សរ ស្រស់បវរ ផ្សេងគ្នាពីរ។

១៦) លុះព្រះបាទ **ជ័យវម៌្ម** ទិវង្គត
រាជវង្សផុត ដោយព្រះនាង **ជ័យទេវី**
ឡើងសោយរាជ្យ ហើយបន្ត ដែនប្រឹថពី
បែកជាពីរ សង្គ្រាមញី ក្លាយជាវាល។

១៧) សតវត្ស ទីប្រាំបួន យុគសំខាន់
**ជ័យវម៌្ម** **ទី២**ស្ដេច ម្ចាស់ចក្រវាល
ជាទេវរាជ ភ្នំគូលែន ដ៏ត្រកាល
អភិបាល ពីកេរកាល គ្រងទុកដាក់។

១៨) គេមិនឃើញ មានចារឹក ចារជាថ្មី
ខ្មែរគប្បី រូបរួមជា អាណាចក្រ
នយោបាយ និងដែនដី ដោយស្មោះស្ម័គ្រ
អាណាចក្រ អង្គរសក រាជឥន្ទ្រ។
១៩) អង្គរថ្កើង ព្រោះខ្មែរយើង មានអ្នកប្រាជ្ញ
ស៊ូអង់អាច ព្រាហ្មណ៍**សិវ-** **កៃវល្យ**
ចាត់ពិធី ទេវរាជ លិង្គសិរៈ
សក្ការៈ និងជាអ្នក បុរោហិត។
២០) រចនាបថ **ភ្នំគូលែន** រស់រវើក
ផុសកក្រើក ជាសិល្បៈ ល្អវិចិត្រ
តក្កកម្ម មានកម្មី ច្នៃប្រឌិត
ដូចនិមិត្ត ពីអាកាស ស្ថានព្រះឥន្ទ។
២១) ភាសាខ្មែរ ចាស់អង្គរ លើសិលា
ដូចមានចា រឹក**ព្រះគោ** រាជ្យព្រះ**ឥន្ទ្រ-**
**វម៌្ម១** **ឥស្វរ** អង្គអមរិន្ទ
មានបំណិន សាងប្រាសាទ រាជបាគង។
២២) រចនាបថ ព្រះគោថ្មី ល្អឥតខ្ចោះ
ដូចព្រះប្រោះ ផ្តែរចម្លាក់ ឥតមានឆ្លង
សត្វមករ វេញត្របាញ់ នាគរាជផង
គ្រុឌចម្លង ឱ្យព្រះឥន្ទ ជិះដំរី។
២៣) ហរិហ រលយ ជាធានី
ស្រស់គ្មានពីរ មានបារាយណ៍ លើលោកី
ឥន្ទ្រត ដាកនី រួមភក្តី
កើតជោគជ័យ **កម្ពុជទេស** ប្រាសាទរាជ។

២៤) លុះព្រះបាទ **ឥន្ទ្រវម៌្ម** ទ្រង់សុគត
សង្គ្រាមផុត ជួយស្ដេចថ្មី ឡើងសោយរាជ្យ
គឺព្រះបាទ **យសោវ-** **ម៌្ម**ធិរាជ
អធិរាជ នៃធានី យសោធរៈ។

២៥) បារាយណ៍ថ្មី យសោធ រតដាក
សាងសង់ដាក់ នៅកណ្ដាល លលៃល័ក្ខ
ភ្នំបាខែង រាងសាជី ទីពំនាក់
ឧទ្ទិសស្ម័គ្រ ព្រះមាតា និងបិតា។

២៦) តួអក្សរ ស្រស់បវរ គួរបេតី
ល្អលើសស្រី គ្មានអ្វីដូច កន្និដ្ឋា
រាងរាវ្លួត ដូចកិន្នរ ពីសួគ៌ា
គ្រីសិទ្ធា ស្វស្តិទា ជយបានយល់។

២៧) **ភ្នំបាខែង** រចនាបថ ប្រាសាទថ្មី
ចំមណ្ឌល រាជធានី ទីមង្គល
លើកំពូល ព្រះសុមេរុ មានរេហ៍ពល
មិនពិភាល់ ឈានទៅដល់ រដ្ឋកាលថ្មី។

២៨) ស្ដេច**ហស៌-** **វម៌្ម១** ជួយឡើងគ្រង
ជាបុត្រច្បង បន្ទវេន មានរស្មី
តែព្រះអង្គ បានគ្រងរាជ្យ ពេលដ៏ខ្លី
អនុជ**ត្រី** **ឦសាន**ឡើង គ្រងបន្ត។

២៩) នៅ**កោះកេរ** មានព្រះបាទ **ជ័យវម៌្ម**
**ចតុ**ស្ដម្ភ ធូលីជេង ព្រះកម្រ
សាងប្រាសាទ ធំកណ្ដាល វាលលំហ
ជាជីពចរ អាណាចក្រ ថ្មីបុរាណ។


youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៣០) **ឆោកគគីរ** គឺជាទី ធានីថ្មី
ជាវិថី ទៅប្រាសាទ ក្ងូថ្មើងថ្កាន
មានចម្លាក់ **ភារតៈ** ទេវស្ថាន
**ទុរយោធនៈ** **ពលរាមៈ** និង**ភិមៈ**។

៣១) តែវិបត្តិ ស្នងរាជ្យវង្ស បានកើតឡើង
លើកតម្កើង បុត្រទី២ **រាជេន្ទ្រ**
រាជធានី មក**យសោ-** **ធបុរៈ**
**ភទិន្ទ្រា** **សិវាចារ្យ** ជារាជគ្រូ។

៣២) សិលាចា រឹកចាំក្រុង បក្សីស្គួគ៌
ជាកាព្យតួ រឿងនិទាន ពី«**កម្ពុ**»
រួមមេត្រី នាង «**មេរា**» ស្វាយម្ភូ
ដែលគិតគូរ ពីប្រវត្តិ **កម្ពុជទេស**។

៣៣) **ភ្នំសណ្ដក** ប្រាសាទថ្មី ល្បីសុសសាយ
ពីព្រេងនាយ « **គិរបុរៈ**» អាទិទេព
សំស្រ្កឹត មានពណ្ណរាយ ចារកាព្យទេព
គម្ពីរវេទ ផ្ដល់ចំណេះ ដល់ខេមរា។

៣៤) សិល្បៈខ្មែរ **ប្រែរូប**ដែរ ជាប្រាសាទ
មានវិមាត្រ សមាមាត្រ ក្បាច់រចនា
ឯ**មេបុណ្យ** ខាងកើតវិញ ស្រស់ដូចផ្កា
ព្រហ្មសាសនា ចារពាក្យកាព្យ មានសម្រស់។

៣៥) ជេន្ទ្រវម៌្ម ដូចព្រះចន្ទ ពេញបូរមី
ស្រស់ដូចស្រី ទេពអប្សរ ក្ងូរទឹកដោះ
បរិសុទ្ធ សន្ដានរាជ វង្សស្ម័គ្រស្មោះ
ស្ដម្ភឥតខ្ចោះ សមជាបុត្រ ព្រះនគរ។


youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៣៦) **បន្ទាយស្រី** **កវីយជ្ញ-** **វរាហៈ**
ជាបុរៈ និវាសស្ថាន ព្រះឥសូរ
ពណ៌ផ្កាឈូក ល្អវិសេស ខាងក្បាច់ក្បូរ
ព័ទ្ធដោយគូ ដូចគំនូរ ស្រីគ្រប់លក្ខណ៍។

៣៧) ផ្តែរប្រាសាទ យ៉ាងសុក្រឹត ជិតឧត្តម
សសរស្តម្ភ មានលាយឡំ ភ្ញីទំពាក់
សសរពេជ្រ រាងអដ្ឋកោណ និងនរៈ
សិង្ហសីហៈ នាគពត់ពេន រូបរាហូ។

៣៨) ព្រាហ្មណ៍បង្រៀន អក្សរសិល្ប៍ អក្សរសាស្ត្រ
ចេះជ្រៅជ្រះ ចេះដឹកនាំ ជាគំរូ
គម្ពីរវេទ វេទង្គៈ អាគមូ
តន្ត្រយូរ វេយ្យាករណ៍ សិល្បៈទាន។

៣៩) សក្តិមាន៤ ព្រាហ្មណឯក ព្រាហ្មណទោ
ព្រាហ្មណ៍ត្រិណោ ចត្វារិ ចារ្យប្រធាន
ជាតួឯក បានចូលរួម វិភាគទាន
ប្រទេសបាន ថ្កុំថ្កើងថ្កាន អារ្យធម៌។

៤០) **ជ័យវម៌្ម** **បញ្ច**ពិជ ឡើងបន្ត
ព្រាហ្មណ៍កម្រ បន្តជួយ ស្តេចមានធម៌
រៀបពិធី «**មហាធ្នូរ**» «ទីក្សា»ជ័រ
នៅយសោ ធបុរៈ រាជធានី។

៤១) កូនមន្ត្រី រៀនជាមួយ នឹងអាចារ្យ
ខំសិក្សា មានឱហាត ចេះសំភី
សាងប្រាសាទ ធ្លាក់ចម្លាក់ លើប្រឹថពី
ទុកជាទី សក្ការៈ បូជាព្រះ។


youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៤២) មើលវិមាន អាកាសផុស លើវេហាស៍
ព្រះវិហារ តាកែវមាន ចារឹកព្រះ
សំស្រ្កឹត បណ្ដុះចិត្ត ឱ្យខ្មែរឈ្នះ
បួងសួងព្រះ សូមជម្នះ ឈ្នះអស់មារ។

៤៣) **សិវាចារ្យ** អធិការ ខាងសីលធម៌
បញ្ចូពណ៌ ចេះអស់ធម៌ មហិមា
តពូជពង្ស ព្រាហ្មណ៍**សិវ-** **កៃវល្យា**
រាជកុលា មហាមន្ត្រី ផ្ទៃករោម។

៤៤) សតវត្ស ទី១១ ចូលមកដល់
**ឧទយា-** **ទិត្យវម៌្ម** ឡើងក្រុង
កលិយុគ ដណ្ដើមរាជ្យ លើផ្ទៃក្រោម
**ជ័យវរ-** **វម៌្ម**និង **សុរិយា**។

៤៥) ព្រះអាទិត្យ តាមការពារ ចែងសែងសូ
ព្រះបាទ**សូ-** **រ្យវម៌្ម** ខំពុះពារ
មាននាម**ឯក** ភ្នំជងរែក មិនរួញរា
ព្រះរាជា អភិសេក ជាចក្រពត្តិ។

៤៦) យុទ្ធវិទូ ដឹកនាំសឹក ដំចំណាន
ខ្មែរថ្កើងថ្កាន រួបរួមជាតិ ប្រតិព័ទ្ធ
សាងប្រាសាទ ដែនសុវណ្ណ ភូមិហ៊ុមព័ទ្ធ
លែងប្រាស់ព្រាត់ ពីគ្រួសារ សន្តិភាព។

៤៧) កោះនាហ្មឹន សព្វមន្ត្រី ផឹកសម្បថ
មិនឱ្យក្បត់ ព្រះរាជា ភក្ដីភាព
ត្រូវសម្ដែង ពីក្ដីស្មោះ យ៉ាងសុភាព
ស្ដេចទ្រង់ជ្រាប ដោយកម្ចាត់ ជនក្បិយ។


youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៤៨) រាជគ្រូ**ស**- **ទាសិវ** អ្នកបណ្ឌិត
មានគំនិត អភិសេក នឹងប្អូនស្រី
ព្រះរាជា ព្រះនាម**វី**- **រលក្ស្មី**
រួមមេត្រី មានភក្តី ស្មោះគ្រប់គ្រា។

៤៩) ទូលបង្គំ សូមសច្ចា កតញ្ញូ
សុខចិត្តប្តូរ ជីវិតលុះ អស់សង្ខារ
ស្វាមីភក្ត្រ មហាក្សត្រ ព្រាហ្មណាចារ្យ
លុះសុរិយា និងព្រះចន្ទ ផុតរលត់។

៥០) ប្តេជ្ញាច្បាំង ខ្មាំងសត្រូវ ដែលឈ្លានពាន
គម្ហែងហ៊ាន ច្បាំងតទល់ ចិត្តមោះមុត
បម្រើការ ពារដោយចិត្ត បរិសុទ្ធ
ស៊ូមិនរត់ សុខចិត្តស្លាប់ ទាំងក្រុមពួក។

៥១) សូមសច្ចា ប្រណិធាន មហាក្សត្រ
មិនគោរព ពាក្យសម្បថ ធ្លាក់នរក
សាមសិបពីរ អស់កាលយូរ ដូចដូជក
ជរាបណា នៅអាទិត្យ និងព្រះចន្ទ។

៥២) ប្រាសាទឃ្លាំង ព្រះវិហារ បដិមា
លើវេហាស៍ ដូចបក្សា ហើរមកកាន់
«**គ្រី គិខ** **រេគូរ**» មានកំណាន់
ល្អដូចចន្ទ គោបុរៈ បញ្ចពិធ។

៥៣) ភវល័យ ព្រះសិវៈ ដៃ១០រាំ
រួចផ្តែផ្តាំ ខេមរជន ឱ្យប្រតិស្ឋ
សាងបន្ត ព្រះបាទ**ឧ**- **ទយាទិត្យ**
ក្បូរក្បាច់ពិត ពិពណ៌នា ទេវកថា។


youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៥៤) ព្រះអង្គបាន លើកតម្កើង អស់អ្នកប្រាជ្ញ
នៅក្នុងរាជ្យ មានអ្នកចេះ ដ៏អស្ចារ្យ
**ទិវាករ** **ភវិន្ទ្រៈ** ចេះគាថា
**ភទ្រេទស្វៈ** **សូមឱ្យកើត** **ជាខ្មែរទៀត**។

៥៥) **ភ្នំជីសូរ** គ្រីសូយ៉ៀ ប៉្វៀត
ប្រតិព័ទ្ធ ប្រាង្គប្រាសាទ មិនចង់ឃ្លាត
អាទិទេព សែងតារា រះព្រោងព្រាត
មិនរវាត **ចង់កើតទៀត** **ជាជាតិខ្មែរ**។

៥៦) **ចាត់ជំបង** ជាវិស័យ នៃអង្គរ
ចម្លាក់ថ្ម នៃប្រាសាទ **ចារសែតខ្មែរ**
សិវលិង្គ «**សូរិយ** **ម៉ែសូរែ**»
«ជយក្សេត្រ» ជាព្រះនាម ប្រាសាទពិត។

៥៧) វត្តឯកភ្នំ ជាបណ្តុំ សិលារស់
មានចារឈ្មោះ **យោគិស្វ** **របណ្ឌិត**
អ្នកកសាង **តិមបុរៈ** ចងជាប់ចិត្ត
បាននៃបនិត្យ ទេពអប្សរ ស្ថានសួគ៌រាជ្យ។

៥៨) លុះព្រះបាទ **សូរ្យវម៌្ម** ទិវង្គត
**ឧទ័យា-** **ទិត្យវម៌្ម** ឡើងសោយរាជ្យ
សាងប្រាសាទ នៅ**តិម័យ** រីកអំណាច
ខ្លាំងខ្លួបខ្លាច ខ្មែរសុខដុម ក្នុងបុរៈ។

៥៩) **ស្តុកកក់ធំ** ទីប្រជុំ ប្រវត្តិសាស្ត្រ
ចារខ្មែរចាស់ ដោយព្រាហ្មណ៍**ស-** **ទាសិវ**
អក្សរសិល្ប៍ សំស្ក្រឹត កាព្យទេវៈ
ជួយបញ្ជាក់ ពង្សាវតារ កម្ពុជរដ្ឋ។

៦០) ព្រះបាទ**បរ** **មេស្វរៈ** ទេវរាជ
ឡើងសោយរាជ្យ នៅ**មហេ-** **ន្ទ្របព៌ត**
ក្លាយទៅជា មហាក្សត្រ ចក្រពត្តិ
ចាំចេះស្ទាត់ គម្ពីរមន្ត សូត្រសំដែង។

៦១) មានតែព្រាហ្មណ៍ ពីសន្តាន **កៃវល្យ**
ដែលជាអ្នក រៀបពិធី កម្រតេង
ចាត់តាំងស្រុក ប្រតិស្ឋាន ព្រះគម្តែង
ជាកំស្តេង បុរោហិត ចេះយ៉ាងច្បាស់។

៦២) ខ្មែរចាស់ក្លាយ ជាភាសា ចារចារឹក
ជួយរំលឹក កត់ត្រាទុក ប្រវត្តិសាស្ត្រ
ប្រទានដី តាំងលំនៅ តារាសាស្ត្រ
តែខ្មែរចាស់ កម្ចីច្រើន ពីសំស្ក្រឹត។

៦៣) **ចេត្តលំ** **មេស្តិបុ** **ឈ្យានាំជា**
**តោហំក** **ម្ទេជេទ្រុតមិ** បុណ្យមានឫទ្ធិ
ខ្ញុំប្រាថ្នា កើតមកនៅ កម្ពុជាពិត
ខំប្រព្រឹត្ត អំពើល្អ ថ្វាយសិរៈ។

៦៤) ព្រះ**ហស់-** **វម៌្ម៣** ឡើយសោយរាជ្យ
តែអំណាច បានបាត់ទៅ មហីធរៈ
រាជវង្សថ្មី ជ័យវម៌្ម មានតេជះ
តារារៈ ដូចព្រះចន្ទ ពេញបូរមី។

៦៥) **ទិវាករ** **បណ្ឌិត**ត្រូវ បានតែងតាំង
ជួយកម្លាំង ជាព្រះគ្រូ អង្គចក្រី
ហើយជួសជុល និងស្ថាបនា ប្រាសាទថ្មី
ព្រះបាទជ័យ មានអនុជ ស្ទួងប្រឹថពី។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៦៦) ព្រះនាម**ធរ**- **ណីន្ទ្រវរ្ម័ន** ពុទ្ធតម្រេក
អភិសេក **ទិជយេ** - **ន្ទ្រលក្ស្មី**
អាណាចក្រ អង្គរមាន រាជវង្សពីរ
**នឫបតី**- **ន្ទ្រវរ្ម័ន** នៅអង្គរ។

៦៧) ខាងសិល្បៈ សាងប្រាសាទ មានបាពួន
ផ្ដាលាក់ខ្លួន ប្រាសាទភ្នំ មានទម្រ
មានកំផែង គោបុរៈ ស្រស់បវរ
នាគលម្អ បញ្ចពណ៌ ក្បាច់រុក្ខជាតិ។

៦៨) ក្បាច់បាពួន មានហោជាង កន្ទុយជ្រុង
ទុកបម្រុង រចនា ភ្ញីធម្មជាតិ
យកទៅសាង ព្រះវិហារ ទីបួនទៀត
វល្លិរុក្ខជាតិ យកលម្អ គោបុរៈ។

៦៩) សូរិយា លើមេឃា បញ្ចពណ៌
បើកទំព័រ សករាជថ្មី តារារះ
រូបរួមជាតិ ជាធ្លុងមួយ សែងត្រចះ
ត្រចែងរះ **សូរ្យ**- **វរ្ម័ន២**។

៧០) សាង**អង្គរ** ទេវស្ថាន ព្រះវិស្ណុ
ព្រះពិធូរ ប្រាសាទថៅ សាយទេវទី
ធម្មានន្ទ បដិមា ល្អគ្មានពីរ
គួរជាទី មនោរម្យ លើផែនដី។

៧១) **ទិវាករ** ព្រាហ្មណ៍កម្រ បណ្ឌិតពិត
រួមរក្សារឹត ភក្ដីភាព មានបារមី
មានពុទ្ធិ ចិបុលិ ស្អាតលើសស្រី
លើលោកិយ បម្រើក្សត្រ ប្រាំព្រះអង្គ។


youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | |
|---|---|---|---|
| ៧២ ) | **ធូលីជើង** | **កម្រតេង** | ជាងារថ្មី |
| | ភក្ត្រប្រិមប្រិយ | រាងរាជសី | ចិត្តអាចអង់ |
| | ដឹកប្រទ្បាយ | សាងស្រះទឹក | ដោយផ្ចិតផ្ចង់ |
| | ល្អត្រចង់ | សេដ្ឋកិច្ចរីក | ជាតិថ្កើងថ្កាន ។ |
| ៧៣ ) | ប្រាសាទខ្មែរ | ឈានទៅដល់ | កំពូលហើយ |
| | ឱខ្មែរអើយ | សាងប្រាសាទ | ពីបូរាណ |
| | គួរស្ញប់ស្ញែង | រំភើបចិត្ត | ឥតឧបមាន |
| | ក្នុងលោកគ្មាន | ទេវស្ថាន | ល្អពិតៗ ។ |
| ៧៤ ) | ក្បាច់ចម្លាក់ | ឆ្លាក់រចនា | បថអង្គរ |
| | ស្រស់លម្អ | កំពូលប្រាង្គ | បញ្ចូពិធ |
| | ទេពអប្សរ | រាំកំដរ | វិបរិត |
| | រំជួលចិត្ត | ស្ថានព្រះឥន្ទ្រ | និងទេវៈ ។ |
| ៧៥ ) | ថែវប្រាសាទ | លម្អដោយ | ផ្ទាំងចម្លាក់ |
| | ដែលមានឆ្លាក់ | រឿងរាមកេរ្តិ៍ | ភារតៈ |
| | ចម្លាក់លៀន | ចម្លាក់លោត | អប្សរៈ |
| | ទិវាករៈ | ជាកំពូល | បញ្ញាញាណ ។ |
| ៧៦ ) | ស្តេចបន្ត | **ធរណី-** | **ន្ទ្រវម៌្ម** |
| | **សោវម៌្ម** | ពុទ្ធសាសនិក | មហាយាន |
| | អង្គទី២ | ព្រះធរណី | បុត្រក្លាហាន |
| | ពេលនោះមាន | អ្នកជ្រែករាជ្យ | ស្តេចសុគត ។ |
| ៧៧ ) | **ជយវធ៌ន** | ព្រះអម្ចាស់ | ជាមេទ័ព |
| | គ្មានទេទ្រព្យ | មានតែចិត្ត | ស្មោះមោះមុត |
| | ចេញទៅច្បាំង | នៅចម្ប៉ា | គ្មានតក់ស្លុត |
| | ចប់ប្រយុទ្ធ | ពេលត្រឡប់ | ហួសពេលហើយ ។ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៧៨) ត្រិភូវនា ទិត្យវម៌្ម បានជ្រែករាជ្យ
យកអំណាច គ្មានកោតខ្លាច បន្តិចឡើយ
រាស្ត្រភ័យភិត បាត់សាមគ្គី ទុក្ខគ្មានស្បើយ
ខ្មែរចុះខ្សោយ ខ្មាំងសត្រូវ ចូលឈ្លានពាន។

៧៩) ចុងសតវត្ស ទី១២ ចាមវាយលុក
បុកសម្រុក វាយអង្គរ ទាំងបំពាន
ជយវរ៌ធន វាយទ័ពចាម ដែលទន្ទ្រាន
ជោគជ័យបាន អភិសេក ជារាជា។

៨០) **ជយវរ្ម័** **ទីប្រាំពីរ** ស្តេចធរណី
ប្រសូតពី វង្សក្សត្រិយ៍ «**ត្រីភុវ្ទជ**»
មាតានាម «**ត្រីជយចូ** **ឌាមណិ**»
ស្អាតដូចជា ដួងព្រះចន្ទ ភ្ញំហេមពាន្ត។

៨១) សម្តីទ្រង់ ពីរោះដូច តួរ្យតន្ត្រី
ព្រះហឫទ័យ ស្រឡាញ់សត្វ មិនបំពាន
ព្រះបិតា **ធរណីន្ទ្រ** ជាព្រះនាម
**ទី២**បាន ឡើងសោយរាជ្យ មហិធរៈ។

៨២) ព្រះអង្គជា ព្រាហ្មណ៍ប្រសើរ ដើរដូចគ្រុឌ
ជឿព្រះពុទ្ធ រូបសម្ផស្ស ដូចសិរៈ
មានកេរ្តិ៍ឈ្មោះ ក្រអូបសាយ ជាទេវៈ
មានវិរៈ ភាពអង់អាច និងប្រាជ្ញា។

៨៣) **ជយវរ្ម័** **ទីប្រាំពីរ** ពូជចម្បាំង
មានកម្លាំង មហិមា ព្រះចេស្តា
ដូចដំរី ប្រជាប្រិយ ហើយក្លៀវក្លា
ដូចបក្សា ហិចហោះហើរ លើអាកាស។


youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | |
|---|---|---|---|
| ៨៤) | សេចក្ដីសុខ | ទុក្ខប្រជា | ទ្រង់យល់យង់» |
| | ជាទុក្ខទ្រង់ | សុខព្រះអង្គ | តែងប្រកាស |
| | បញ្ញាញាណ | ចំណេះដឹង | ខ្ពង់ខ្ពស់ណាស់ |
| | ចេះយ៉ាងច្បាស់ | សំស្រឹត | យុទ្ធចម្បាំង។ |
| ៨៥) | ស្ដេចបានសាង | **អង្គរធំ** | រាជធានី |
| | ល្អឥតពីរ | លើធរណី | ឱ្យខ្មែរខ្លាំង |
| | តំណាងលោ | កេស្វរៈ | ជាកម្លាំង |
| | ខ្មែរលែងច្បាំង | សាងប្រាសាទ | ច្រើនសន្ធឹក។ |
| ៨៦) | មានបាយ័ន | មានស្រះស្រង់ | មានតាព្រហ្ម |
| | តាសោមធំ | បន្ទាយក្ដី | ព្រះខ័នឫទ្ធិ |
| | បន្ទាយឆ្មារ | បានាគព័ន្ធ | ជ្រុងប្រសិទ្ធ |
| | ជ័យមានឫទ្ធិ | ធម្មសាលា | ព្រះពុទ្ធពាន់។ |
| ៨៧) | រចនា | បថ**បាយ័ន** | សិល្បៈខ្ពស់ |
| | ជាតិខ្មែររស់ | ព្រោះខ្មែរមាន | បញ្ញវ័ន្ត |
| | សាលារៀន | ផ្ដល់ចំណេះ | ចេះគ្រប់គ្រាន់ |
| | ខ្មែររួសរាន់ | ជ្រះថ្លាក្នុង | ពុទ្ធសាសនា។ |
| ៨៨) | ធម្មកាយ | សម្ភោគកាយ | និម្មាណកាយ |
| | ជាការថ្វាយ | បង្គំពុទ្ធ | កិស្វរា |
| | មហេសី | **ត្រីរាជេ-** | **ន្ទ្រទេវា** |
| | ដូចជាផ្កា | ព្រះសុមេរុ | និងគង្គា។ |
| ៨៩) | ទ្រង់ជាក្សត្រិយ៍ | មានសិទ្ធិ | និងប្រីតិ |
| | មានបីតិ | ស្មោះស្វាមី | រាល់ទិវា |
| | ថ្វាយតង្វាយ | ព្រះជិនស្រី | បដិមា |
| | មហិមា | រួចយាងចូល | ព្រះនិព្វាន។ |

៩០) មហេសី អង្គទីពីរ ជាអ្នកប្រាជ្ញ
គេកោតខ្លាច ព្រោះចំណេះ ចេះលើសព្រាហ្មណ៍
ព្រះនាង**ឥ-** **ន្ទ្រទេវី** ជាព្រះនាម
គ្រូបង្រៀន នៅតាព្រហ្ម ធម៌ព្រះពុទ្ធ។

៩១) ពុទ្ធសាសនា មហាយាន ត្រៃរតនៈ
កិស្សរៈ បារមិតា និងព្រះពុទ្ធ
ពោធិសត្វ សង្គ្រោះលោក គ្មានពិរុទ្ធ
ច្បាំងព្រះពុទ្ធ នៅពេលចប់ រាជ្យព្រះជ័យ។

៩២) ខ្មែរងាកមក យកព្រហ្មញ្ញ ជាសាសនា
បដិមា ត្រូវកម្ទេច កប់ក្នុងដី
កាត់ព្រះកេស ឆ្លាក់ទៅជា ព្រះឥសី
**បន្ទាយភ្លី** កប់ព្រះពុទ្ធ ជាច្រើនទៀត។

៩២) សតវត្ស ទី១៣ ចាប់ផ្ដើមចុះ
ខ្មែរចំណុះ ចុះទៅជឿ ថេរវាទ
ប្រើបាលី លែងប្រើប្រាស់ សំស្ក្រឹតទៀត
មានវិវាទ ខាងភាសា និងសាសនា។

៩៣) ថេរវាទ លើកតម្កើង សាសនារដ្ឋ
ព្រាហ្មណ៍ខ្ចាត់ព្រាត់ ព្រោះតែខ្មែរ លែងត្រូវការ
អារ្យធម៌ វប្បធម៌ និងភាសា
បានអ្នកណា ជួយអប់រំ ខ្មែរអង្គរ។

៩៤) សតវត្ស ទី១៤ គ្មានចារឹក
ចាររំលឹក អានុភាព ព្រះនគរ
ព្រោះបាត់បង់ បញ្ញវន្ត ដែលស្មោះសរ
ខ្មែរធ្លាក់ក្រ ខ្សត់កម្រ ខាងប្រាជ្ញា។

៩៥) ឱអង្គរ ស្រស់បវរ បាត់រស្មី
នៅបារមី ព្រះវិស្ណុ ថែរក្សា
តែវប្បធម៌ អារ្យធម៌ និងសាសនា
ក្លាយទៅជា ដុំសិលា គ្រាន់រំលឹក។

៩៦) កូនខ្មែរអើយ កុំកន្តើយ ចាំវាសនា
ជនខេមរា ត្រូវក្លៀវក្លា កុំនៅស្ងឹក
មានឱហាត មានមារយាទ ជាពន្លឹក
នឹករលឹក ដល់ពូជខ្មែរ សាងអង្គរ។

៩៧) ខ្មែរធ្លាប់ថ្កើង ព្រោះខ្មែរយើង ចេះចងចាំ
តាមចំណាំ ខ្មែរស៊ូទ្រាំ សាងនគរ
ខ្មែរមានចិត្ត មានគំនិត មានឈាមជ័រ
ផ្សព្វផ្សាយធម៌ សាងប្រាសាទ ពីបុរាណ។

៩៨) យើងជាខ្មែរ ត្រូវការពារ អារ្យធម៌
និងវប្បធម៌ ពីដូនតា ឱ្យក្សេមក្សាន្ត
បង្រៀនកូន ចៅឱ្យចេះ ខ្មែរបុរាណ
រហូតមាន ព្រះអាទិត្យ និងព្រះចន្ទ។

# បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ក្នុងនីតិកាលទី៦នៃរាជរដ្ឋាភិបាលកម្ពុជា។

លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នៅឆ្នាំ១៩៨៨ និងបណ្ឌិតនៅឆ្នាំ១៩៩១ ផ្នែកសេដ្ឋកិច្ចអន្តរជាតិពីវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិក្រុងម៉ូស្គូ ព្រមទាំងសញ្ញាបត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពីវិទ្យាស្ថានធានារ៉ាប់រង(CII) ប្រទេសអង់គ្លេស និងវិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី(MII)។ នៅឆ្នាំ២០១២ លោកបណ្ឌិតទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រអន្តរជាតិពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច នៅកម្ពុជា និងពីសាកលវិទ្យាល័យLyon II នៃសាធារណរដ្ឋបារាំង ព្រមទាំងទទួលបានវិញ្ញាបនបត្រផ្នែកនីតិសមុទ្រពីបណ្ឌិត្យសភា Rhodes ផ្នែកនីតិសាស្ត្រ និងគោលនយោបាយសមុទ្រ។ នៅឆ្នាំ២០១៨ លោកបណ្ឌិត ទទួលបានសញ្ញាបត្របណ្ឌិតផ្នែកអប់រំពីសាកលវិទ្យាល័យចូឡាឡុងកន។

លោកបណ្ឌិតធ្លាប់បានបម្រើការងារក្នុងបេសកកម្មការទូត និងក្នុងវិទ្យាស្ថានស្រាវជ្រាវ ជាអ្នកវិភាគនយោបាយ និងសេដ្ឋកិច្ច។ ចាប់តាំងពីឆ្នាំ១៩៩៩មក លោកបណ្ឌិតបានចូលបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទទួលបន្ទុកការងារសំខាន់ៗរួមមាន អ្នកសម្របសម្រួលការងារស្រាវជ្រាវនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងជាអនុប្រធានទី១នៃនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ។ បន្ទាប់មក ក្នុងឆ្នាំ២០០១ លោកបណ្ឌិតបានត្រូវតែងតាំងជាអគ្គលេខាធិការរងទទួលបន្ទុកគោលនយោបាយរួមមាន គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ ហិរញ្ញវត្ថុ កិច្ចការអាស៊ាន ឧស្សាហកម្ម ហិរញ្ញវត្ថុ ការវិភាគសេដ្ឋកិច្ច និងទទួលបន្ទុកក្នុងការសម្របសម្រួលជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ពីឆ្នាំ២០០៤ដល់ឆ្នាំ២០១០ លោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកបណ្ឌិតធ្លាប់ចូលរួមកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ានបូកបី ពីឆ្នាំ២០០០ដល់២០១០។ ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣ លោកត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងតួនាទីនេះលោកធ្លាប់ធ្វើជាតំណាងប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាល G20 ក្នុងឋានៈដែលប្រទេសកម្ពុជាជាប្រធានអាស៊ាន នៅឆ្នាំ២០១២។ លោកបណ្ឌិតក៏បម្រើការងារជាអ្នកសម្របសម្រួល កិច្ចពិភាក្សាគោលនយោបាយរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយធនាគារអភិវឌ្ឍន៍អាស៊ី(ADB) មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។

ក្នុងតំណែងជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ដែលជាស្ថាប័នខាងផ្នែកគោលនយោបាយសេដ្ឋកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា លោកបណ្ឌិតបានសរសេរឯកសារគោលនយោបាយជាច្រើន និងបានអមដំណើរ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្និសីទអន្តរជាតិ ដូចជា មហាសន្និបាតអង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ព័ន្ធ កិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងវេទិកាអន្តរជាតិជាច្រើនទៀត។

លោកបណ្ឌិតបាននិពន្ធសៀវភៅជាច្រើនក្បាល ជាភាសាខ្មែរ អង់គ្លេស និងបារាំងស្តីអំពីការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា និងហិរញ្ញវត្ថុសាធារណៈ ហើយស្នាដៃចុងក្រោយក្រោមចំណងជើងថា Cambodian Economy: Charting the Course for a Bright Future ត្រូវបានជ្រើសរើសបោះពុម្ពផ្សាយ ដោយវិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍(ISEAS) នៃប្រទេសសិង្ហបុរី។ ស្នាដៃចុងក្រោយរបស់លោក គឺ «អក្សរសិល្ប៍ និងភាសាខ្មែរសម័យមុនអង្គរ និងសម័យអង្គរ តាមរយៈសិលាចារឹក»។


youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ស្នាដៃរបស់អ្នកនិពន្ធ

១- L'Économie du Cambodge: La lutte pour le développement, 2005

២- Essais économiques, 2007

៣- Les finances publiques du Cambodge, 2007

៤- Cambodia: Recent Macroeconomic and Financial Sector Development, 2008

៥- Three Essays on Macroeconomic Management of Cambodia, 2008

៦- Introduction to Insurance, 2008

៧- ម៉ាក្រូសេដ្ឋកិច្ច - ឆ្នាំ២០០៩

៨- Public Finance in Cambodia, 2009

៩- ហិរញ្ញវត្ថុសាធារណៈ - ឆ្នាំ២០០៩

១០- ប្រាសាទព្រះវិហារ - ឆ្នាំ២០០៩

១១- Cambodian Economy: Chartering the Course of a Brighter Future. A Survey of Progress, Problems and Prospects, 2009

១២- L ' économie du Cambodge: Nouvelles frontières du développement socio-économique, 2010

១៣- Regards sur le différend maritime khméro-thaïlandais à la lumière de la jurisprudence internationale, 2012

១៤- ទស្សនាទានស្តីពីវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់ដ៍ ក្នុងបរិបទនៃយុត្តិការអន្តរជាតិ - ឆ្នាំ២០១៣

១៥- សេដ្ឋកិច្ចកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង ៖ វឌ្ឍនភាព បញ្ហាប្រឈមនិងទស្សនវិស័យទៅអនាគត - ឆ្នាំ២០១៥

១៦- កំណែទម្រង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព - ឆ្នាំ២០១៦

១៧- គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃប្រទេសកម្ពុជា នាសម័យទំនើបនៅសម័យ សាធារណរដ្ឋប្រជាមានិតកម្ពុជា( ទសវត្សរ៍ ឆ្នាំ១៩៨០ ) - ឆ្នាំ២០១៧

១៨- នីតិអន្តរជាតិសេដ្ឋកិច្ច - ឆ្នាំ២០១៧

១៩- Series of Lectures in Public International Law, 2018

២០- សិក្សាសង្ខេបស្តីពីទស្សនវិជ្ជា - ឆ្នាំ២០១៨

២១- Droit International Économique, 2018

២២- Education Reform in Cambodia, 2018

២៣- វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរក្នុងការលើកកម្ពស់អំណាននៅកម្ពុជា - ឆ្នាំ២០១៩

២៤- ប្រវត្តិសាស្រ្តកម្ពុជា ក្នុងបរិបទសកលលោក - ឆ្នាំ២០១៩

២៥- អក្សរសិល្ប៍ និងភាសាខ្មែរសម័យមុនអង្គរ និងសម័យអង្គរ តាមរយៈសិលាចារឹក -ឆ្នាំ ២០២០




កំណាព្យខ្មែរមានប្រវត្តិដ៏យូរលង់ណាស់មកហើយ។ សិលាចារឹកចាប់ពីសតវត្សទី៦ដល់ទី១៤ជាភាសាសំស្ក្រឹត សុទ្ធតែរៀបរៀង ពាក្យកាព្យ ដែលហៅថា “ កាវ្យៈ ”។ នៅសតវត្សទី១០ កំណាព្យភាសា សំស្ក្រឹតខ្មែរឈានដល់ចំណុចកំពូល។ វណ្ណកម្មអក្សរសិល្ប៍កំណាព្យ ខ្មែរកណ្តាលចាប់ពីសតវត្សទី១៥ដល់ទី១៨ មានរឿង “ រាមកេរ្តិ៍ ” និង “ ល្បើកអង្គរវត្ត ” (១៦២០)។ សិលាចារឹកជ័យ នន្ទ (១៧០១) តែង ជាបទព្រហ្មគីតិ កុជង្គលីលា និងកាកគតិ។ អក្សរសិល្ប៍កំណាព្យ ភាសាខ្មែរសម័យទំនើបឈានដល់ចំណុចកំពូលនៅចុងសតវត្សទី១៩ និងដើមសតវត្សទី២០ ដូចជារឿង “ សព្វសិទ្ធិ ” (១៨៩៩) និពន្ធដោយលោក ហ៊ឹនកក្តីអក្សរ តន់ និងរឿង “ ទុំទាវ ” (១៩១៥) ដោយព្រះបទុមថេរសោម។ ដូច្នេះកំណាព្យខ្មែរ គឺជាបេតិក-ភណ្ឌជាតិ ដ៏សំខាន់ដែលបុព្វបុរសខ្មែរបន្សល់ទុក ហើយកូនខ្មែរជំនាន់ក្រោយ មានកាតព្វកិច្ចអភិរក្ស និងអភិវឌ្ឍបន្តទៀត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews